# FAQs – Visa ShopSmall Campaign Offers

**សំណួរ៖** តើយុទ្ធនាការរបស់ Visa ដែលមានឈ្មោះថា ShopSmall campaign គឺជាអ្វី**?**
**ចម្លើយ៖** ក្រុមហ៊ុន Visa បានចាប់ផ្តើមកម្មវិធីផ្តល់ជូនពិសេសដល់អតិថិជន វីសាកាត ដែលធ្វើប្រតិបត្តិការទូទាត់នៅទីតាំងអាជីវកម្មធុនតូច និងធុនកណ្តាលក្នុងស្រុកទូទាំងប្រទេស ពិសេសខេត្តសៀមរាប ដើម្បីគាំទ្រការចំណាយប្រចាំថ្ងៃនៅតាមហាងអាជីវកម្មតូចៗ តាមរយៈការប្រើវិធីទូទាត់ចំរុះ។

- Tap ដើម្បីទូទាត់ជាមួយ Visa កាតដែលមានសុពលភាព ប្រភេទប័ណ្ណឥណពន្ធ **(Debit)** ប័ណ្ណឥណទាន **(Credit)** ឬ prepaid កាតដែលចេញដោយធនាគារដែលមានអាជ្ញាបណ្ណនៅកម្ពុជា។
- ស្កេនដើម្បីទូទាត់ជាមួយ Visa កាតដែលមានសុពលភាពនិងចេញដោយធនាគារ ABA, ធនាគារ ACLEDA និង ធនាគារឯកទេស AEON នៅក្នុងប្រទេសកម្ពុជាពី **app** ធនាគារផ្ទាល់។




**សំណួរ៖** តើខ្ញុំអាចចូលរួមយុទ្ធនាការនេះបានយ៉ាងដូចម្តេច**?**
**ចម្លើយ៖**ដើម្បីចូលរួមក្នុងយុទ្ធនាការនេះ អ្នកគ្រាន់តែធ្វើការទូទាត់ដោយប្រើ “Tap” ឬ ស្កេនជាមួយ Visa កាតចំនួន 5ដង 10ដង ឬ 15ដង ប្រតិបត្តិការក្នុងមួយខែ នៅតាមហាងអាជីវកម្មដែលចូលរួម។ បន្ទាប់មក អ្នកអាចចូលទៅកាន់គេហទំព័រទទួលរង្វាន់ដើម្បីទទួលយករង្វាន់របស់អ្នក។

- ប្រតិបត្តិការទូទាត់ទាំងអស់ត្រូវតែបានដំណើរការតាមប្រព័ន្ធ VisaNet (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ)។
- មានតែប្រតិបត្តិការទូទាត់ដែលបានជោគជ័យប៉ុណ្ណោះដែលនឹងត្រូវបានគេចាត់ទុកថាត្រូវតាមលក្ខខណ្ឌក្នុងការទទួលបានរង្វាន់។ ការប្រគល់ទំនិញមកវិញ ការស្នើសុំសងប្រាក់វិញ ឬការលុបចោលប្រតិបត្តិការណាមួយក្រោមហេតុផ្សេងៗ ប្រតិបត្តិការទាំងនោះនឹងមិនអាចដាក់បញ្ចូលក្នុងយុទ្ធនាការនេះទៀតទេ សម្រាប់ប្រតិបត្តិការដែលត្រូវបានសងប្រាក់វិញ ឬលុបចោលនោះ។

**សំណួរ៖** តើយុទ្ធនាការនេះផ្តល់ជូនអ្វីខ្លះដល់អតិថិជន?
**ចម្លើយ៖** អត្ថប្រយោជន៍ក្នុងយុទ្ធនាការនេះមានចំនួនកំណត់ ដោយអនុវត្តតាមគោលការណ៍ មកមុនទទួលបានមុន ហើយអាស្រ័យលើចំនួនប្រតិបត្តិការទូទាត់ដូចខាងក្រោម៖

- សម្រាប់ប្រតិបត្តិច 5 ដងដំបូង ក្នុងមួយខែនឹងទទួលបាន voucher សម្រាប់ភេសជ្ជៈមួយកែវនៅហាងកាហ្វេ Brown។
- សម្រាប់ប្រតិបត្តិការ **5** ដងបន្ទាប់ (ឬប្រតិបត្តិការទី **10**) នឹងទទួលបាន voucher សម្រាប់ភេសជ្ជៈមួយកែវនៅហាងកាហ្វេ Brown **មួយទៀត**។
- សម្រាប់ប្រតិបត្តិការ 15 ដង ក្នុងមួយខែនឹងទទួលបានសំបុត្រមួយសម្រាប់ចូលរួមទិវារត់ប្រណាំងដែលរៀបចំដោយ Cambodia Event Organizer ។

Voucher មិនអាចផ្ទេរ មិនអាចប្តូរ និងមិនអាចសងប្រាក់វិញបានឡើយ។ Voucher នេះមិនអាចប្តូរយកសាច់ប្រាក់ ឬទំនិញផ្សេងបានទេ។ ការផុតកំណត់សុពលភាពរបស់ voucher នេះគិតចាប់ពីថ្ងៃដែលអ្នកបានទទួលបានលេខកូដ voucher។

**សំណួរ៖** តើត្រូវធ្វើដូចម្តេចខ្លះដើម្បីបានការផ្តល់ជូនពីគេហទំព័រ?
**ចម្លើយ៖** អ្នកអាចចូលទៅកាន់គេហទំព័រ **www.visa.com/km_KM/pay-withvisa/shopsmall-campaign.html** ដែលត្រូវបានចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយរបស់យុទ្ធនាការ ដូចជាការបង្ហោះលើបណ្តាញសង្គម App ឬគេហទំព័ររបស់ធនាគារសាមីដែលចេញប័ណ្ណ។ បន្ថែមពីនេះ អ្នកក៏អាចស្កេន QR code លើសម្ភារៈផ្សព្វផ្សាយនៅឯទីតាំងអាជីវកម្មដែលបានចូលរួមដើម្បីចូលទៅកាន់គេហទំព័រនោះផងដែរ។

- អ្នកនឹងត្រូវបញ្ជូនបន្តទៅតំណភ្ជាប់ Visa Offer Page។ ចុចប៊ូតុង “Claim Offer”។
- បញ្ចូលលេខ Visa កាត 8 ខ្ទង់ខាងដើមនិង 4 ខ្ទង់ខាងចុង រួមជាមួយលេខទូរស័ព្ទរបស់អ្នក។
- បញ្ចូលលេខ OTP ដែលបានផ្ញើទៅកាន់លេខទូរស័ព្ទ ឬអ៊ីម៉ែលរបស់អ្នក។
- ការផ្តល់ជូននឹងត្រូវបានបង្ហាញឡើងសម្រាប់អ្នកទទួលយក។
- លេខកូដនឹងត្រូវបានបង្ហាញជា voucher ដែលអ្នកបានទទួល។
- លេខកូដដូចគ្នានេះក៏នឹងត្រូវផ្ញើសារ SMS ទៅលេខទូរស័ព្ទ ឬអ៊ីម៉ែលដែលបានផ្តល់ផងដែរ។
- Voucher នីមួយៗមានរយៈពេល 60 ថ្ងៃដើម្បីប្តូរយក គឺចាប់ពីខែដែលមានប្រតិបត្តិការដែលធ្វើឲ្យម្ចាស់កាតមានសិទ្ធិទទួលបាន voucher។ ព័ត៌មានលម្អិតអំពី voucher ម្ចាស់កាតអាចរកមើលបាននៅលើគេហទំព័រនៅពេលដែលទទួលបាន voucher។
- ប្រតិបត្តិការដែលមានសិទ្ធិទទួលបានរង្វាន់មានន័យថាចំនួនទឹកប្រាក់នៃប្រតិបត្តិការទូទាត់បានជោគជ័យ ដោយប្រើ Tap ឬ ស្កេនទូទាត់តាម **Visa** កាតនៅហាងអាជីវកម្មដែលបានចូលរួមក្នុងរយៈពេលមួយខែ។

- ប្រសិនបើម្ចាស់កាតមិនបានចូលទៅយក voucher នៅក្នុងរយៈពេលកំណត់ទេ ម្ចាស់កាតនោះនឹងបាត់សិទ្ធិទទួលបាន voucher នៅក្នុងខែដដែលនោះ។
- ក្រុមហ៊ុន Visa ធនាគារសាមី៉ និងអាជីវករនឹងមិនទទួលខុសត្រូវចំពោះ ការពន្យាពេល ការបាត់បង់ ឬការខូចខាតក្នុងការផ្តល់ voucher ទេ។

សម្រាប់សំណួរ ឬចម្ងល់ផ្សេងៗ សូមទំនាក់ទំនងទៅកាន់ផ្នែកសេវាកម្មបម្រើអតិថិជនរបស់ Razorpay តាមអ៊ីម៉ែល Visaoffersupport@razorpay.com។ ចំណាំថា Visa និងធនាគារសាមី៉នឹងមិនទទួលខុសត្រូវចំពោះសេវាកម្មអតិថិជនដែលពាក់ព័ន្ធនឹងយុទ្ធនាការនេះទេ។ ដើម្បីជៀសវាងការយល់ច្រឡំ ការទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មអតិថិជនជាទំនួលខុសត្រូវរបស់ Razorpay តែមួយប៉ុណ្ណោះ។

**សំណួរ៖** តើត្រូវធ្វើដូចម្តេចខ្លះដើម្បីអាចប្រើ voucher?

**ចម្លើយ៖**

Voucher សម្រាប់ភេសជ្ជៈនៅហាងកាហ្វេ Brown

- បង្ហាញលេខកូដរបស់ voucher ពីសារ SMS ឬ អ៊ីម៉ែល នៅហាង Brown ណាមួយដើម្បីទទួលបានភេសជ្ជៈក្តៅ ឬត្រជាក់ ទំហំតូចមួយកែវ (លើកលែងតែទឹកផ្លែឈើ)។
- Voucher នេះមានសុពលភាព 3 ខែ គិតចាប់ពីថ្ងៃទទួលបាន voucher ។
- ប្រសិនបើ voucher នេះមិនត្រូវបានប្រើប្រាស់ក្នុងរយៈពេលនៃសុពលភាពរបស់វាទេ voucher នឹងត្រូវផុតកំណត់។ voucher ដែលបានផុតកំណត់ មិនអាចជំនួសថ្មីបានឡើយ។

សំបុត្រសម្រាប់ចូលរួមទិវារត់ប្រណាំងដែលរៀបចំដោយ Cambodia Event Organizer

- voucher កូដអាចប្រើសម្រាប់ប្តូរយកសំបុត្រចូលរួម /ចុះឈ្មោះ សម្រាប់កម្មវិធី ឬកីឡាប្រណាំងណាមួយដែលមាននៅលើគេហទំព័រ Cambodia Event Organizer នៅពេលដែលបានប្រើ voucher ។
- ម្ចាស់កាតអាចទទួលបាន voucher ដោយចុចលើរង្វាន់នោះ ដែលនៅទីនោះពួកគេនឹងមានជម្រើស “Claim” voucher ។ បន្ទាប់មក ម្ចាស់កាតនឹងត្រូវបានភ្ជាប់ទៅកាន់គេហទំព័រ (“Website”) ដើម្បីបញ្ចូលលេខកាត និងព័ត៌មានផ្សេងៗសម្រាប់ទទួល voucher ដែលអាចប្រើប្រាស់បាន។

**សំណួរ៖** ខ្ញុំបានចូលទៅកាន់គេហទំព័រដោយជោគជ័យ ប៉ុន្តែមិនមាន voucher សម្រាប់ខ្ញុំ។

**ចម្លើយ៖**

- សូមប្រាកដថា អ្នកមានចំនួនប្រតិបត្តិការទូទាត់ត្រូវតាមលក្ខខណ្ឌ។
- voucher នឹងបង្ហាញឡើង 7 ថ្ងៃ បន្ទាប់ពីពេលដែលអ្នកបានទូទាត់ប្រតិបត្តិការចុងក្រោយ។
- សូមចូលទៅកាន់គេហទំព័រផ្តល់ជូនរង្វាន់ក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីខែដែលអ្នកបានធ្វើការទូទាត់ដើម្បីយក voucher ។

- ប្រសិនបើអ្នកនៅតែមិនអាចឃើញ voucher ទោះបីជាមានសិទ្ធិទទួលបានក៏ដោយ សូមទាក់ទងមកផ្នែកបម្រើសេវាកម្មអតិថិជនតាម Visaoffersupport@razorpay.com ។

**សំណួរ៖** តើប្រភេទអាជីវកម្មបែបណាខ្លះដែលចូលរួមក្នុងកម្មវិធីនេះ**?**
**ចម្លើយ៖** "ហាងអាជីវកម្មដែលចូលរួម" រួមបញ្ចូល (ប៉ុន្តែមិនមានកំណត់) ហាងលក់ទំនិញតូចៗ ឬប្រភេទសេវាកម្មដែលផ្តល់ដោយប្រជាជនក្នុងស្រុកដូចជា៖ តូបលក់ម្ហូបអាហារតូចៗ ហាងលក់សម្លៀកបំពាក់និងក្រណាត់ ហាងលក់វត្ថុអនុស្សាវរីយ៍ ហាងសិប្បកម្ម ហាងលក់គ្រឿងទេស និងសេវាដឹកជញ្ជូនក្នុងស្រុកដូចជា តុកតុក។ ឬយោងតាមនិយមន័យរបស់ Visa ហាងអាជីវកម្មដែលចូលរួមត្រូវបានចាត់ជាប្រភេទអាជីវកម្មដែលមានស្លាក MVV នៅក្នុងប្រព័ន្ធរបស់ Visa ហើយការលក់ប្រចាំឆ្នាំតិចជាង 60,000 ដុល្លារអាមេរិក។